ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ÷ ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែកញ្ញា ឆ្នាំ២០១៤

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែកញ្ញា ឆ្នាំ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមពីឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ ។



ជាកិច្ចចាប់ផ្តើម ឯកឧត្តម **គង់ វិបុល** ប្រធានអង្គប្រជុំបានសំដែងអំណរសាទរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់លំដាប់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារ ដែលសម្រេចបានប្រចាំខែកញ្ញា ឆ្នាំ២០១៤ និងជំរុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ សមាជិកអង្គប្រជុំដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឲ្យខិតខំជម្នះការលំបាក និងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានល្អប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែងនិងអនុវត្តវិធានការនានា សំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៤ ។

ក្នុងខែកញ្ញា ឆ្នាំ២០១៤ នេះអគ្គនាយកដ្ឋានពន្ធដារប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ៣១៧.៨៨៤ លានរៀល (ប្រមាណជា ៧៩,៥ លានដុល្លារ)។ ប្រសិនបើប្រៀបធៀបទៅនឹងចំណូលពន្ធប្រចាំខែកញ្ញា ឆ្នាំ២០១៣ ឃើញថា ការប្រមូលចំណូលពន្ធដារបង់ចូលថវិកាជាតិ ប្រចាំខែកញ្ញា ឆ្នាំ២០១៤ នេះមានការកើនឡើងស្មើនឹង ១០,៨%។

ក្នុងរយៈពេលប្រាំបួនខែនៃឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធដារនិងបង់ចូលថវិកាជាតិបានចំនួនស្មើនឹង ៨០,៦% នៃគោលដៅកំណត់ដោយច្បាប់ ក្នុងនោះ ថវិការដ្ឋសម្រេចបានចំនួនស្មើនឹង ៨១,៩% និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សម្រេចបានចំនួនស្មើនឹង ៧២,៥%។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៣ ឃើញថាការប្រមូលចំណូលពន្ធដារចូលថវិកាជាតិសម្រាប់ឆ្នាំ២០១៤នេះ មានការកើនឡើងចំនួនស្មើនឹង១៨,២%។

ប្រសិនបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ចំណូលតាមប្រភេទពន្ធសំខាន់ៗ មានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន÷ ពន្ធលើប្រាក់បៀវត្សកើនឡើងចំនួនស្មើនឹង ៣០,៦% ពន្ធលើប្រាក់ចំណេញកើនឡើងចំនួនស្មើនឹង ២៦,៧% អាករលើតម្លៃបន្ថែមកើនឡើងចំនួនស្មើនឹង ១៣,៩% និងអាករពិសេសកើនឡើងចំនួនស្មើនឹង ១០,៩%។

បើប្រៀបធៀបទៅនឹងរយៈពេល ០៩ខែ ដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ចំណូលពន្ធតាមសកម្មភាពអាជីវកម្មមានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន÷ផ្នែកផលិតភេសជ្ជៈកើនឡើងប្រមាណ ១៧,៣% សេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២១,៣% ទូរគមនាគមន៍កើនឡើងប្រមាណ ៣,៧% ផ្នែកស្ថាបត្យកម្មនិងសំណង់កើនឡើងប្រមាណ ៦៣,៧% ផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ៣២,៤% ផលិតសម្លៀកបំពាក់កើនឡើងប្រមាណ ៤៥,៣% នីហរណអាហរណ៍កើនឡើងប្រមាណ ១៣,៩% ផ្នែកសណ្ឋាគារ និងផ្ទះសំណាក់កើនឡើងប្រមាណ ៤៦,១% ផលិតថ្នាំជក់កើនឡើងប្រមាណ ៣,៨% អាជីវកម្មអចលនទ្រព្យកើនឡើងប្រមាណ ៩២,១% លក់ភេសជ្ជៈកើនឡើង ៣៣,៦% លក់សម្ភារការិយាល័យកើនឡើងប្រមាណ ៤៣,៨% ផលិតម្ហូបអាហារកើនឡើងប្រមាណ ៧៧,៧% ផ្នែកលក់គ្រឿងយន្តកើនឡើងប្រមាណ ៦០,៩% លក់ផលិតផលឱសថកើនឡើងប្រមាណ ១៨៣,៤% និងលក់គ្រឿងសំណង់កើនឡើងប្រមាណ ១.១៥៨,២%។

ក្នុងការពិភាក្សា អង្គប្រជុំបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា I-ពិនិត្យពិភាក្សាលើរបាយការណ៍លទ្ធផលប្រមូលចំណូលពន្ធប្រចាំខែរបស់នាយកដ្ឋាន និងសាខាពន្ធដារ ខេត្ត-ខណ្ឌ II- វឌ្ឍនភាពនៃការចាត់អាជីវកម្មដ្ឋានជាប់ពន្ធតាមរបបម៉ៅការទៅរបបស្វ័យប្រកាស ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ និងការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៤។ III-ការចុះបញ្ជីសហគ្រាសតាមប្រព័ន្ធថ្មី និងការធ្វើបច្ចុប្បន្នភាពសហគ្រាស VI-វឌ្ឍនភាពការងារផ្នែកតាមផែនការសកម្មភាពដោះស្រាយបញ្ហាជាក់ស្តែងរបស់អគ្គនាយកដ្ឋានពន្ធដារ VII-បញ្ហាផ្សេងៗ ដូចជា ការពង្រឹងការផ្សព្វផ្សាយការបំពេញ កាតព្វកិច្ចសារពើពន្ធតាមរយៈសិក្ខាសាលាជូនដល់អ្នកជាប់ពន្ធ ពង្រឹងការប្រកាសបង់ពន្ធ ពង្រឹងការធ្វើសវនកម្មជាដើម ។

ដើម្បីប្រមូលចំណូលបានគ្រប់តាមផែនការច្បាប់ និងដើម្បីធានាបាននូវភាពជឿទុកចិត្តផ្នែកថវិកាសម្រាប់បម្រើឲ្យកិច្ចការគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ អគ្គនាយកដ្ឋានបានដាក់ចេញនូវទិសដៅ និងវិធានការមួយចំនួនដែលមានកន្លងមកដើម្បីអនុវត្ត ។



ជាកិច្ចបញ្ចប់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលមានការកើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់អស់លោកជាប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់ និងមន្ត្រីពន្ធដារទាំងអស់ឲ្យខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌ វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធ ដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសម្រេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ។

**អគ្គនាយកដ្ឋានពន្ធដារ**